# របាយការណ៍ស្តីអំពីវគ្គ
# ពង្រឹងសមត្ថភាពការងារគ្រប់គ្រងទិន្នន័យ
# ថ្ងៃទី ០៤-០៦ ខែធ្នូ ឆ្នាំ ២០១៨
# សណ្ឋាគារមណ្ឌលគិរី ខេត្ត មណ្ឌលគិរី

**Training Capacity Building Data Management**
**04 - 06 Decemember 2018**
**Mondolkiri Hotel, Mondolkiri**

វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់មន្ត្រីគ្រប់គ្រងទិន្នន័យ និងអ្នកបញ្ចូលទិន្នន័យ ថ្នាក់ខេត្ត/ក្រុងបានប្រព្រឹត្តទៅនៅ សណ្ឋាគារមណ្ឌលគីរី ខេត្តមណ្ឌលគីរី ថ្ងៃទី ០៤-០៦ ខែ ធ្នូ ឆ្នាំ ២០១៨ ដែលរៀបចំឡើងដោយផ្នែកគ្រប់គ្រងទិន្នន័យនៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែកនិងកាមរោគ ដោយទទួលបាននូវការឧបត្ថម្ភថវិកាពីមូលនិធិសកល។

វគ្គបណ្តុះបណ្តាលនេះគឺធ្វើឡើងក្នុងគោលបំណងពង្រឹងសមត្ថភាពដល់ មន្ត្រីគ្រប់គ្រងទិន្នន័យគ្រប់ខេត្តក្រុង និងអ្នកបញ្ចូលទិន្នន័យទាំងអស់យល់ច្បាស់អំពីការងារដែលបាន និងកំពុងអនុវត្តន៍កន្លងមក ជាពិសេសការប្រមូលទិន្នន័យ ការគ្រប់គ្រងទិន្នន័យ ការបំពេញលើទំរង់អ្នកជំងឺអេដស៍ ការប្រើប្រាស់លេខកូដ ការផ្តល់ព័ត៌មានត្រឡប់ ការប្រើប្រាស់ Tools ផ្សេងៗដើម្បីប្រមូលទិន្នន័យអ្នកជំងឺអេដស៍ ការប្រមូលរបាយការណ៍ប្រចាំត្រីមាស និងប្រព័ន្ធ Database: សំរាប់គ្រប់គ្រងជំងឺកាមរោគ (STI) ការផ្តល់ប្រឹក្សាធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់(VCCT) និងការគ្រប់គ្រងអ្នកជំងឺអេដស៍ (Pre-ART/ART) នៅទូទាំង ២៥ខេត្តក្រុង និងដំណើរការផ្លាស់ប្តូរបទពិសោធន៍ការងារគ្រប់គ្រងទិន្នន័យ ព្រមទាំងពិភាក្សា និងដោះស្រាយបញ្ហាដែលកើតមានកន្លងមក។ ព្រោះនេះជាការងារមួយសំខាន់ណាស់ ក្នុងការពង្រឹងគុណភាពទិន្នន័យ ដើម្បីអោយយើងមានទន្និន័យត្រឹមត្រូវជាក់លាក់ អាចយកមកវិភាគ ប្រើប្រាស់ក្នុងមន្ទីរពេទ្យ និងក្នុងខេត្ត ក៏ដូចជាថ្នាក់ជាតិផងដែរ។

វគ្គបណ្តុះបណ្តាលនេះមានការចូលរួមពីមន្ត្រីផ្នែកគ្រប់គ្រងទិន្នន័យ ២៥ខេត្តក្រុង (៣៧នាក់) និង អ្នកបញ្ចូលទិន្នន័យ (៥០នាក់), មន្ត្រីមកពី PASP, Linkages មន្ត្រីមកពីមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែកនិងកាមរោគរួមមាន: លោកវេជ្ជ.សំរិទ្ធ សុវណ្ណារិទ្ធ ជាប្រធានការិយាល័យបច្ចេកទេស លោកវេជ្ជ. ង៉ូវ បូរ៉ាជាប្រធានផ្នែកថែទាំជំងឺអេដស៍ លោកវេជ្ជ.កាអឿន ចិត្រា ជាមន្ត្រីជាន់ខ្ពស់នៃការិយាល័យបច្ចេកទេសលោក.កែវ វណ្ណៈជាមន្ត្រី B-IACM Focal point លោកវេជ្ជ.គឹម ផ៊ុណ្ណ ជាប្រធានផ្នែកផែនការ តាមដាន និងរបាយការណ៍ លោក ទេព រ៉ូម៉ាំងលោក ឡេង ច័ន្ទរតនា លោក កែ អាងហេង លោក លាង សុផាន់ណា លោកស្រី ឡាញ់ ចរិយា លោក ប៊ូ វឌ្ឍនៈ លោក ៣៧ រដ្ឋា ជាមន្ត្រីផ្នែកគ្រប់គ្រងទិន្នន័យ លោកស្រី វ៉ី វន្នី មន្ត្រីរដ្ឋបាលជាន់ខ្ពស់ លោក ជា ណារិទ្ធ និង លោករស់ ផូរ៉ាវុធជាមន្ត្រីគណនេយ្យ លោក ឌិន សិទ្ធិ ជាមន្ត្រីរដ្ឋបាល លោក ខែម មៅ លោកម៉ក់ ប៊ុនថន លោក សុខ ចំរើន លោក ស៊ឹមម៉ា ជាអ្នកបើកបរ និង លោកស្រី ស៊ុន ឌីណា ជាអ្នកសម្របសម្រួលខេត្តមណ្ឌលគិរី ។



**គ្រូបង្គោល:**

**សមាសភាពចូលរួមពីមជ្ឈមណ្ឌលជាតិរួមមាន**

| | |
|---|---|
| លោកវេជ្ជ.សំរឹទ្ធ សុវណ្ណារិទ្ធ | ប្រធានការិយាល័យបច្ចេកទេសនៃមជ្ឈមណ្ឌលជាតិ |
| លោក ឡេង ច័ន្ទរតនា | មន្ត្រីផ្នែកគ្រប់គ្រងទិន្នន័យនៃមជ្ឈមណ្ឌលជាតិ |
| លោក កែ អាងហេង | មន្ត្រីផ្នែកគ្រប់គ្រងទិន្នន័យនៃមជ្ឈមណ្ឌលជាតិ |
| លោក លាង សុផាន់ណា | មន្ត្រីផ្នែកគ្រប់គ្រងទិន្នន័យនៃមជ្ឈមណ្ឌលជាតិ |
| លោកស្រី ឡាញ់ ចរិយា | មន្ត្រីផ្នែកគ្រប់គ្រងទិន្នន័យនៃមជ្ឈមណ្ឌលជាតិ |
| លោក ប៊ូ វឌ្ឍនៈ | មន្ត្រីផ្នែកគ្រប់គ្រងទិន្នន័យនៃមជ្ឈមណ្ឌលជាតិ |
| លោក ពៅ រដ្ឋា | មន្ត្រីផ្នែកគ្រប់គ្រងទិន្នន័យនៃមជ្ឈមណ្ឌលជាតិ |
| លោកស្រី វឿ វណ្ណី | មន្ត្រីផ្នែករដ្ឋបាល និងធនធានមនុស្សនៃមជ្ឈមណ្ឌលជាតិ |

**អ្នកសម្របសម្រួល:**

| | |
|---|---|
| **លោក** ជា ណារិទ្ធ | មន្ត្រីផ្នែកគណនេយ្យនៃមជ្ឈមណ្ឌលជាតិ |
| **លោក** រស់ ភូវ៉ារុធ | មន្ត្រីផ្នែកគណនេយ្យនៃមជ្ឈមណ្ឌលជាតិ |
| លោក ឌិន សិទ្ធ | មន្ត្រីផ្នែករដ្ឋបាលនៃមជ្ឈមណ្ឌលជាតិ |

**អ្នកបើកបរ**

| | |
|---|---|
| លោក ខេម មៅ | អ្នកបើកបរ |
| លោក ម៉ក់ ប៊ុនថន | អ្នកបើកបរ |
| លោក សុខ ចំរើន | អ្នកបើកបរ |
| លោក ស៊ឹម ម៉ា | អ្នកបើកបរ |

**ថ្ងៃទី១: ០៤ ខែ ធ្នូ ឆ្នាំ២០១៨**

- ការចុះឈ្មោះសិក្ខាកាម និងការអញ្ជើញមកដល់របស់សិក្ខាកាម

វគ្គបណ្តុះបណ្តាលបានចាប់ផ្តើមដំណើរការនៅវេលាម៉ោង ៨ និង ៣០នាទី ដោយមានការចូលរួមសំដែងមតិសំណេះសំណាល និងបើកវគ្គ ដោយលោកប្រធានការិយាល័យបច្ចេកទេស នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងលោកអនុប្រធានមន្ទីរសុខាភិបាលខេត្តមណ្ឌលគីរី រួចមកក៏មានការបង្ហាញអំពី:

- Overview of HIV/AIDS prevention, care and treatment in Cambodia
- Introduction, status and scaling-up plan for 115 system
- Result and challenges of STI data collection
- Result and challenges of VCCT data collection
- Introduction, status and scaling-up plan for Remote printing
- Challenges and status of New ART database
- Prevention database

**ថ្ងៃទី២: ០៥ ខែ ធ្នូ ឆ្នាំ២០១៨**

- ម៉ោង៨:00ដល់ម៉ោង៨:១៥ គឺជាការសរុបនិងសង្ខេបពីការងារដែលបានបង្ហាញនៅថ្ងៃទីមួយ ដែលក្នុងនោះយើងបានផ្តល់ឱកាសអោយអ្នកចូលរួមទាំងអស់លើកជាសំនួរលើការងារណាដែលមិនទាន់យល់រឺក៏យល់មិនទាន់ច្បាស់មកពិភាក្សា និងពន្យល់បន្ថែម។ បន្ទាប់មកក៏មានការបង្ហាញអំពី:

- Understanding of Data definition, data collection, data type and data quality
- Introduction to Drag and drop tool
- Status of Barcode implementation

- B-IACM status and scaling-up plan
- Basic data analysis (descriptive statistic)
- Group work on descriptive statistic
- Group work presentation

**ថ្ងៃទី៣: ០៦ ខែ ធ្នូ ឆ្នាំ២០១៨**

- ម៉ោង៨:00ដល់ម៉ោង៨:១៥ គឺជាការសរុបនិងសង្ខេបពីការងារដែលបានបង្ហាញនៅថ្ងៃទីពីរ ដែលក្នុងនោះយើងបានផ្តល់ឱកាសអោយអ្នកចូលរួមទាំងអស់លើជាសំនួរលើការងារណាដែលមិនទាន់យល់រឺក៏យល់មិនទាន់ច្បាស់មកពិភាក្សា និងពន្យល់បន្ថែម។បន្ទាប់មកក៏មានការបង្ហាញអំពី:

- Presentation on Administrative documentation
- How to maintenance your computer and other device

- Data use and presentation
- Group work on data use and presentation
- Group presentation and feedback
- Concept of Health Equity

**បញ្ហាដែលក្រុមនិមួយៗបានលើក**

ផ្នែករបាយការណ៍ STI, HTC, VCCT, BCC, Pre-ART/ART ៖

- អ្នកធ្វើរបាយការណ៍ផ្ញើរយឺត
- អ្នកធ្វើរបាយការណ៍ខ្លះអត់ធ្វើរបាយការណ៍HTC
- ពិបាក់ទាក់ទងអ្នកធ្វើរបាយការណ៍
- ការបំពេញក្នុងបញ្ជី និងរបាយការណ៍មិនបានត្រឹមត្រូវ
- OD ខ្លះពុំបានជួយសម្របសំរួលក្នុងការប្រមូលរបាយការណ៍
- ការទទួលលទ្ធផល CD4/Viral load យឺតយ៉ាយពី Labo

ផ្នែកប្រព័ន្ធទិន្នន័យ(Data Base System):

- គ្រូពេទ្យបំពេញព័ត៌មានលើទំរង់អ្នកជំងឺ មិនទាន់បានពេញលេញ
- អ្នកផ្តល់ព្រឹក្សាអត់ស្ទូវមកបំពេញការងារនៅសេវា VCCT
- អត់មានលេខកូដ Pre-ART នៅលើទម្រង់ឯកសាររបស់អ្នកជំងឺ
- លទ្ធផលតេស្តសរសេរមិនច្បាស់
- កុមារធំជាង១៨ឆ្នាំខ្លះពុំទាន់បញ្ជូនទៅមនុស្សធំ
- បាត់ឯកសារអ្នកជំងឺ

- សំណូមពរ
  - សូមជួយកែ Error សំរាប់ Database ART ថ្មីអោយបានឆាប់
  - សុំអោយមាន Message alert Requite and Optional Fields
  - ថែម Viral load Alert ក្នុងរបាយការណ៍ប្រចាំថ្ងៃ
  - មាន CQI សំរាប់កុមារ
  - សុំ Install QR Code and Termal printer ដើម្បីផ្តល់លទ្ធផល Viral load អោយបានលឿន
  - សុំអោយមានវគ្គបណ្តុះបណ្តាល Basic data analysis
  - សូមអោយមានវគ្គបណ្តុះបណ្តាលបន្ថែមដល់អ្នកចុះបញ្ជី និងមន្ត្រីដែលពាក់ព័ន្ធ
  - សូមអោយមាន Internet ប្រើគ្រប់ Sites
  - Printer, UPS ខូច សុំថ្មី
  - បើកប្រាក់ខែអោយបានលឿន
  - សូមអោយមានវគ្គបណ្តុះបណ្តាលនេះយ៉ាងហោចណាស់១ឆ្នាំម្តង

## សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានទទួលការសិក្សារយៈពេល៣ថ្ងៃកន្លងមក ឃើញថាមន្ត្រីគ្រប់គ្រងទិន្នន័យ និងមន្ត្រីបញ្ចូលទិន្នន័យថ្នាក់ខេត្ត-ក្រុងទាំងអស់ បានយល់ដឹងបន្ថែមលើការងារថ្មីៗមួយចំនួនដែលមជ្ឈមណ្ឌលជាតិ បាននឹងកំពុងរៀបចំដាក់អោយប្រើប្រាស់មានជាអាទ៍: New Pre-ART/ART, STI, New VCCT, HTC, Prevention DB , Exposed Infant, B-IACM, 115 System, QR Code and Thermal printing. តាមរយៈការបង្ហាញរបស់គ្រូបង្គោលមកពីមជ្ឈមណ្ឌលជាតិ និងការយកចិត្តទុកដាក់របស់សិក្ខាកាម វគ្គបណ្តុះបណ្តាលនេះអាចជួយបង្កើននូវចំណេះដឹង របស់មន្ត្រីគ្រប់គ្រង

ទិន្នន័យ និងមន្ត្រីបញ្ចូលទិន្នន័យថ្នាក់ខេត្ត-ក្រុងក្នុងការប្រមូល, ពិនិត្យ និងធ្វើអោយរបាយការណ៍កាន់តែមានភាពសុក្រិតថែម ទៀតមុននឹងផ្ញើរមកកាន់មជ្ឈមណ្ឌលជាតិ។

ចំពោះការធ្វើតេស្តមុនវគ្គសិក្សាចំនួនភាគរយដែលសិក្ខាកាមអាចឆ្លើយសំនួរបានត្រឹមត្រូវមាន ៨០ភាគរយ ប៉ុន្តែបន្ទាប់ពីបានឆ្លងកាត់វគ្គបណ្តុះបណ្តាលនេះមកឃើញថាសមត្ថភាពរបស់សិក្ខាកាមទាំងអស់អាចឆ្លើយសំនួរត្រឹមត្រូវបានច្រើនជាង ៩៨ភាគរយនេះអាចបញ្ជាក់អោយកាន់តែច្បាស់ថាវគ្គបណ្តុះបណ្តាលនេះពិតជាមានសារៈប្រយោជន៍ដល់សិក្ខាកាមដែលជាមន្ត្រីគ្រប់គ្រងទិន្នន័យ និងមន្ត្រីបញ្ចូលទិន្នន័យខេត្ត-ក្រុងពិតប្រាកដមែន។

វគ្គបណ្តុះបណ្តាលនេះបានបញ្ចប់នៅវេលាម៉ោង១៧:០០ ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨ ដោយលោកប្រធានការិយាល័យបច្ចេកទេស បានប្រកាសបិទវគ្គបណ្តុះបណ្តាលនេះក្រោមបរិយាកាសរីករាយ និងភាពស្និទស្នាលជាទីបំផុត ហើយបានជូនពរអោយសិក្ខាកាមទាំងអស់ធ្វើដំណើរត្រលប់ទៅកាន់គេហដ្ឋាន វិញប្រកបដោយសេចក្តីសុខ និងសុវត្ថិភាព ហើយជាចុងក្រោយបានថតរូបជុំគ្នាដើម្បីទុកជាអនុស្សាវរីយ៍ ។

ធ្វើនៅភ្នំពេញថ្ងៃទី 17 ខែ ធ្នូ ឆ្នាំ២០១៨

អ្នកធ្វើរបាយការណ៍

ឡេង ច័ន្ទរតនា

បានឃើញ និងឯកភាព

ជ.ប្រធានមជ្ឈមណ្ឌលជាតិ

អនុប្រធាន

វេជ្ជ.អ៊ុក_វិជ្ជា